# សម្រាកពេលឈឺ ដែលត្រូវទទួលបាន

## សេចក្តីជូនដំណឹងអំពីសិទ្ធិនិយោជិត

ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥ និយោជិតនៅរដ្ឋម៉ាសាឈូសេត មានសិទ្ធិទទួលបាន និង ឈប់សម្រាកពេលឈឺ។

### នរណាខ្លះមានសិទ្ធិទទួលបានវា?

**និយោជិតទាំងអស់** នៅរដ្ឋម៉ាសាឈូសេត អាចទទួលបានសម្រាកពេលឈឺ។ នេះបូកបញ្ចូលទាំងនិយោជិតពេញម៉ោង មិនពេញម៉ោង បណ្តោះអាសន្ន និង និយោជិតតាមរដូវកាល។

### តើទទួលបានយ៉ាងដូចម្តេច?

- និយោជិតទទួលបាន ១ ម៉ោង សម្រាប់រាល់ការងារដែលបានបំពេញ ៣០ ម៉ោង។
- និយោជិតអាចទទួលបាន និង ប្រើបានរហូតដល់ **៤០ ម៉ោងក្នុងមួយឆ្នាំ** បើគាត់ធ្វើការគ្រប់ម៉ោង។
- និយោជិតដែលមិនបានប្រើសម្រាកពេលឈឺ នៅចុងឆ្នាំ គាត់អាច**ផ្ទេរទៅពេលក្រោយ រហូតដល់ ៤០ ម៉ោង។**
- និយោជិត**ចាប់ផ្តើមទទួលបាន**សម្រាកពេលឈឺ នៅថ្ងៃដំបូងពេលចូលធ្វើការ និង **អាចចាប់ផ្តើមប្រើ**សម្រាកពេលឈឺនេះ ក្រោយចូលធ្វើការបាន ៩០ ថ្ងៃ។

### តើអ្នកបានជាប្រាក់ដែរទេ?

- បើនិយោជកមាននិយោជិត ១១ នាក់ ឬ ច្រើនជាងនេះ សម្រាកពេលឈឺនោះ ត្រូវតែបានប្រាក់។
- ចំពោះនិយោជកមាននិយោជិត ១០ នាក់ ឬតិចជាងនេះ សម្រាកពេលឈឺ អាចបានប្រាក់។
- ប្រាក់សម្រាកពេលឈឺ ត្រូវផ្តល់តាមពេលវេលាដូចគ្នា និង ថ្ងៃដូចគ្នានឹងប្រាក់ឈ្នួលធម្មតាដែរ។

### តើពេលណាទើបអាចប្រើវាបាន?

- និយោជិតអាចប្រើសម្រាកពេលឈឺ នៅពេលគាត់ ឬ កូន ប្តី/ប្រពន្ធ ឪពុក/ម្តាយ ឬ ឪពុក/ម្តាយក្មេកគាត់ឈឺ ឬ មានណាត់ពេទ្យ ឬ ត្រូវដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ។
- ចំនួនម៉ោងសម្រាកពេលឈឺ ដែលនិយោជិតអាចឈប់ម្តងៗ គឺតិចបំផុតគឺមួយម៉ោង។
- សម្រាកពេលឈឺនេះ មិនយកមកប្រើ ជាលេសជំនួសការមកធ្វើការយឺត ដោយមិនបានប្រាប់មុននោះទេ។
- សម្រាកពេលឈឺនេះ មិនអនុញ្ញាតឲ្យប្រើសម្រាប់បំណងអ្វីផ្សេង បើមិនដូច្នេះទេ អាចរងពិន័យ។

### តើនិយោជកអាចមានគោលនយោបាយខុសគ្នាដែរឬទេ?

បាទ/ចាស! អាចមាន។ និយោជកអាចមានគោលនយោបាយផ្ទាល់ខ្លួន អំពីការសម្រាកពេលឈឺនេះ ឬ គោលនយោបាយផ្តល់ប្រាក់សម្រាប់ពេលឈប់សម្រាក ឲ្យតែនិយោជិតអាចប្រើម៉ោងឈប់សម្រាកប្រហែលគ្នា និង ហេតុផលដូចគ្នា និង ការងារដែលមានការការពារ អនុលោមតាមច្បាប់ស្តីពីការទទួលបានសម្រាកពេលឈឺនេះ។

### ការសងសឹក

- និយោជិតដែលប្រើប្រាស់សម្រាកពេលឈឺ មិនអាចរងការបញ្ឈប់ពីការងារ ឬ សងសឹក ដោយសារតែប្រើ ឬ មានបំណងប្រើសិទ្ធិ ដែលច្បាប់ការពារ។
- ឧទាហរណ៍ នៃការសងសឹក រួមមាន៖ មិនឲ្យប្រើ ឬ ពន្យារបើកប្រាក់សម្រាកពេលឈឺ បញ្ឈប់និយោជិត ដកម៉ោងធ្វើការ ឬ ឲ្យការងារលំបាកដល់និយោជិត។

### ការជូនដំណឹង និង លិខិតបញ្ជាក់

- និយោជិតត្រូវជូនដំណឹងទៅនិយោជក នៅមុនសម្រាកពេលឈឺ លើកលែងតែករណីអាសន្នបន្ទាន់ណាមួយ។
- និយោជកអាចតម្រូវឲ្យនិយោជិត **ធ្វើតាមប្រព័ន្ធជូនដំណឹងសមស្របណាមួយ** ដែលនិយោជកបង្កើត។
- បើនិយោជិតមិនមកធ្វើការ ៣ថ្ងៃជាប់ៗគ្នា ឬ ប្រើប្រាស់សម្រាកពេលឈឺ ក្នុងពេលពីសប្តាហ៍នៃការឈប់ពីការងារ និយោជកអាចតម្រូវ និយោជិតឲ្យមានសំបុត្រពេទ្យបញ្ជាក់។

### តើអ្នកមានសំណួរអ្វីដែរទេ?

**សូមទូរស័ព្ទផ្នែកយុត្តិធម៌ការងារ៖** 617-727-3465 សូមមើល www.mass.gov/ago/earnedsicktime

Commonwealth of Massachusetts
Office of the Attorney General
English - July 2016

**អគ្គរដ្ឋអាជ្ញា ពង្រឹងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិស្តីពីសម្រាកពេលឈឺនេះ។**
ការបំពានបទប្បញ្ញត្តិណាមួយ នៃច្បាប់ស្តីពីសម្រាកពេលឈឺនេះ គឺជាការរំលោភច្បាប់។
ការបំពានបទប្បញ្ញត្តិណាមួយ នៃច្បាប់ស្តីពីសម្រាកពេលឈឺ M.G.L. c. 149, §148C, ឬបទប្បញ្ញត្តិ 940 CMR 33.00 ត្រូវអនុវត្តតាមកថាខណ្ឌ (1), (2), (4), (6), និង (7) នៃអនុកថាខណ្ឌ (b) នៃ M.G.L. c. 149, §27C(b) និងរហូតដល់ §150។
**សេចក្តីជូនដំណឹងនេះ មានបំណងដំម្រាបជូនឲ្យបានដឹង។**
អត្ថបទច្បាប់ និង បទប្បញ្ញត្តិនេះទាំងស្រុងមាននៅ **www.mass.gov/ago/earnedsicktime.**